**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តក្រចេះ**
**តុលាការរដ្ឋប្បវេណី**
សំណុំរឿងរដ្ឋប្បវេណីលេខ ១៣២
ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២១
សាលក្រមលេខ ៥៨ "ជ"
ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០២៤

# សាលក្រម
## ក្នុងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តក្រចេះ

បញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០២៤ នៅសាលសវនាការ នៃសាលាដំបូងខេត្តក្រចេះ ដែលមានសមាសភាពចៅក្រមជំនុំជម្រះ ដូចខាងក្រោម ៖

**ចៅក្រមជំនុំជម្រះ**
លោកស្រី [redacted] ចៅក្រម នៃសាលាដំបូងខេត្តក្រចេះ
**ក្រឡាបញ្ជីជំនុំជម្រះ**
លោក [redacted] ក្រឡាបញ្ជី នៃសាលាដំបូងខេត្តក្រចេះ

**-ដើមចោទ៖** [redacted] ។

មានលោកមេធាវី [redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទ ។

**-ចុងចម្លើយ៖** ក្រុមហ៊ុន [redacted] មានទីតាំង [redacted] ភ្នំពេញ តំណាង ដោយឈ្មោះ [redacted] ZHAOTIAN ។

មានលោកមេធាវី [redacted] មានការិយាល័យ [redacted] ។

**អង្គហេតុ និងចំណុចវិវាទ**

**ក.ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ**

១.ទាមទារកុំឱ្យអនុញ្ញាតអនុវត្តដោយបង្ខំចំពោះម្ចាស់បំណុលនៃការអនុវត្តទៅលើដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នលេខ ៤៦៥ "ធ" ដ.រ ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ ។

២.ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ចុងចម្លើយ ។

**ខ.ដំណើររឿងក្ដី និងចំណុចវិវាទ៖**

ខ.១ ការសង្ខេបអំពីរឿងក្ដី៖

កាលពីថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២១ ដើមចោទបានចុះកិច្ចព្រមព្រៀងសហប្រតិបត្តិការដាំដំណាំចេកជាមួយចុងចម្លើយលើដីគម្រូរបស់ចុងចម្លើយដែលមានទំហំសរុប ២.៥០០ (ពីរពាន់ប្រាំរយ) ហិកតា មានទីតាំង ស្ថិតនៅឃុំក្បាលដំរី ស្រុកសំបូរ ខេត្តក្រចេះ ដែលមានរយៈពេលសហការចំនួន ៣០ឆ្នាំ ដោយគិត



Scanned with CamScanner

ចាប់ពីថ្ងៃទី០១ ខែឧសភា ឆ្នាំ២០២១ រហូតដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០៥១ ។ ពាក់ព័ន្ធនឹងការអនុវត្តកិច្ចសហប្រតិបត្តិការខាងលើនេះ ដើមចោទបាននឹងគ្រោងចំណាយនូវដើមទុនវិនិយោគសរុបប្រមាណចំនួន ៤៥០.០០០.០០០ (បួនរយហាសិបលាន)យ័ន ដែលគិតជាប្រាក់ដុល្លារអាមេរិកប្រហាក់ប្រហែលចំនួន ៧២.០០០.០០០ (ចិតសិបពីរលាន)ដុល្លារអាមេរិក (អត្រាប្តូរប្រាក់ក្នុងមួយយ័នស្មើនឹង ០,១៦ ដុល្លារអាមរិក) ។ នៅក្នុងដំណាក់កាលទី១ នៃកិច្ចព្រមព្រៀងខាងលើនេះ ត្រូវអភិវឌ្ឍលើផ្ទៃដីសរុបចំនួន ១០០ (មួយរយ)ហិកតា ជាមួយនឹងទឹកប្រាក់គ្រោងវិនិយោគសរុបចំនួន ១៨.០០០.០០០ (ដប់ប្រាំបីលាន) យ័ន គិតជាប្រាក់ដុល្លារអាមេរិកប្រហាក់ប្រហែលចំនួន ២.៨៨០.០០០ (ពីរលានប្រាំបីសែនប្រាំបីម៉ឺន) ដុល្លារអាមេរិក ។ ក្រោយពីថ្ងៃចុះកិច្ចព្រមព្រៀងខាងលើនេះ ចំពោះដំណាំចេកដែលបានដាំ គិតមកដល់ពេលបច្ចុប្បន្ន ពុំទាន់បានប្រមូលផលនៅឡើយទេ រួមទាំងកំពុងធ្វើការដាំដុះបន្ថែមជាបន្តបន្ទាប់ទៀតផងដែរ។ បន្ទាប់មក នៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២១ តំណាងអយ្យការអមសាលាដំបូងខេត្តក្រចេះ បានចេញលិខិតជូនដំណឹងស្តីពីការអនុវត្តដោយស្ម័គ្រចិត្តលេខ ១៨៥ អ.យ. ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២១ ដែលមានកូនបំណុលនៃការអនុវត្តឈ្មោះ [redacted] GUANHUA និងតតិយជនទាំងអស់ដែលកំពុងស្នាក់នៅជួល អាស្រ័យផលប្រកបអាជីវកម្មផ្សេងៗឱ្យធ្វើការរុះរើឥវ៉ាន់ និងសម្ភារៈផ្សេងៗទាំងអស់ចេញ តាមអំណាចដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នលេខ ៤៦៥ "ធ" ដ.រ ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលធ្វើឱ្យមានការប៉ះពាល់សិទ្ធិ និងផលប្រយោជន៍ស្របច្បាប់របស់ដើមចោទ ។

**ខ.២ អង្គហេតុដែលមានវិវាទ៖**

១-តើលោក GAO GUNANHUA មានសិទ្ធិចុះហត្ថលេខាលើធ្វើកិច្ចព្រមព្រៀងសហប្រត្តិបត្តិការដាំដំណាំចេក ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២១ រវាងក្រុមហ៊ុន[redacted]និងក្រុមហ៊ុន [redacted]?

២-តើដីកាសម្រេចរក្សាការពារចាត់ចែងជាបណ្តោះអាសន្នលេខ៤៦៥ "ធ" ដ.រ ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ ធ្វើឲ្យប៉ះពាល់ដល់ផលប្រយោជន៍របស់ក្រុមហ៊ុនខេមបូខានបាណាណា អេហ្គ្រីខលឆឺរ៍ល ឯ.ក ដែរឬទេ?

**ខ.៣ សេចក្តីថ្លែងការណ៍របស់ភាគី**

-មេធាវីតំណាងដោយអាណត្តិឱ្យដើមចោទបានធ្វើសេចក្តីថ្លែងការណ៍ថា ៖ កាលពីថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២១ កូនក្តីខ្លួនបានចុះកិច្ចព្រមព្រៀងសហការដាំចេកជាមួយ[redacted]លើទំហំផ្ទៃដី ២,៥០០ ហិចតា ដែលមានទីតាំងស្ថិតនៅឃុំ[redacted]ដោយមានការសហការគ្នារហូតដល់ ៣០ឆ្នាំ គិតចាប់ពីថ្ងៃទី០១ ខែឧសភា ឆ្នាំ២០២១ រហូតដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០៥១ ។ ពាក់ព័ន្ធទៅនឹងកិច្ចសហប្រត្តិបត្តិការខាងលើនេះ កូនក្តីខ្លួនបានចំណាយប្រាក់ទៅលើការដាំដំណាំចេកជិត ២០០០០០០ (ពីរលាន)ដុល្លារអាមេរិក ដែលក្នុងការអនុវត្តនៃកិច្ចព្រមព្រៀងនេះ កូនក្តីខ្លួនបានបង់ប្រាក់កក់ចំនួន ២០០០០០ (ម្ភៃម៉ឺន) ដុល្លារអាមេរិកក្នុងមួយឆ្នាំ ឲ្យទៅក្រុមហ៊ុន[redacted]រួចរាល់ព្រមទាំងបានបង់ប្រាក់ថ្លៃឈ្នួលដីផងដែរ និងមានការចំណាយផ្សេងៗ ដូចជាពលកម្ម ការដាំដុះ ក៏ដូចជាលក្ខណៈបច្ចេកទេសក្នុងការគ្រប់គ្រងទៅលើផលដំណាំផងដែរ។ ការបង់នេះ គឺវេរចូលទៅក្នុងគណនីធនាគារផ្ទាល់របស់ក្រុមហ៊ុនចុងចម្លើយ មិនមែនវេរទៅគណនីធនាគាររបស់លោក [redacted]GUNANHUA ទេ។ ប៉ុន្តែ ស្រាប់តែតំណាងអយ្យការអមសាលាដំបូងខេត្តក្រចេះ បានចេញលិខិតជូនដំណឹងស្តីពីការអនុវត្តដោយស្ម័គ្រចិត្តលេខ១៨៥ អ.យ.ក ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២១ ដែលមានកូនបំណុលនៃការអនុវត្តឈ្មោះ [redacted]GUANHUA និងតតិយជនទាំងអស់ដែលកំពុងស្នាក់នៅជួល អាស្រ័យផលប្រកបអាជីវកម្មផ្សេងៗ ឬធ្វើការ្យទាំងឡាយក្នុងទីតាំងដីចំការ និងរោងចក្រខាងលើនេះ ធ្វើការរុះរើ ឥវ៉ាន់ និងសម្ភារៈទាំងអស់ដែលជាកម្មសិទ្ធិរបស់ខ្លួនចេញឱ្យអស់ ព្រមទាំងចាកចេញពីទីតាំងដីចំការ និងរោងចក្រខាងលើនេះ ឱ្យបានមុនថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២១ វេលាម៉ោង ៩៖០០នាទីព្រឹក ជាកំហិត បើមិនដូច្នេះទេតំណាង

អយ្យការនឹងចុះអនុវត្តដោយបង្ខំ តាមអំណាចដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នលេខ ៤៥៦ “ធ” ជ.រ ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ នៅពេលកាលបរិច្ឆេទកំណត់បានមកដល់។ បើពិនិត្យទៅលើលិខិតជូនដំណឹង ស្តីពីការអនុវត្តដោយស្ម័គ្រចិត្តខាងលើនេះ គឺអនុវត្តខុសទៅនឹងខ្លឹមសារនៃសេចក្តីសម្រេចបញ្ជាប់របស់ដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នលេខ ៤៥៦ “ធ” ជ.រ ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ ដោយហេតុថា ត្រង់ចំណុចទី១ នៃដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នខាងលើនេះ បានសម្រេចត្រឹមតែបង្គាប់ឱ្យកូនបំណុលឈ្មោះ [redacted]GUANHUA តែប៉ុណ្ណោះ ដែលជាអ្នកប្រគល់ការគ្រប់គ្រង ប៉ុន្តែ បែរជាតំណាងអយ្យការអមសាលាដំបូងខេត្តក្រចេះ ដែលទទួលបន្ទុកកិច្ចការអាជ្ញាសាលាប្រុងនឹងអនុវត្ត ខ្លឹមសារ នៃសេចក្តីសម្រេចបញ្ជាប់របស់ដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នខាងលើចំពោះតតិយជនផងដែរ។ ដូចនេះ ពាក់ព័ន្ធជាមួយនឹងការអនុវត្ត ការជូនដំណឹងរបស់តំណាងអយ្យការបានធ្វើឱ្យ ប៉ះពាល់ផលប្រយោជន៍សិទ្ធិរបស់កូនក្តីខ្លួន ដើម្បីជៀសវៀងនូវការប៉ះពាល់នូវសិទ្ធិ និងផលប្រយោជន៍កូនក្តីខ្លួនស្របច្បាប់ កាលពីថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២១ ក៏បានដាក់ពាក្យបណ្តឹងតវ៉ាតតិយជន ដូចលោកស្រីចៅក្រមបានរៀបរាប់អំបាញ់មិញ។ ពាក់ព័ន្ធនឹងចំណុចវិវាទដែលតុលាការបានកំណត់ទីមួយ តើលោក [redacted] GUNANHUA មានសិទ្ធិចុះហត្ថលេខាលើធ្វើកិច្ចព្រមព្រៀងសហប្រត្តិបត្តិការដាំដំណាំចេក ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២១ រវាងក្រុមហ៊ុន[redacted] និង[redacted]? ចំពោះចំណុចវិវាទនេះ ខ្លួនសូម ធ្វើសេចក្តីថ្លែងការណ៍បញ្ជាក់ជូនថា ការចុះសហការដាំចេកខាងលើនេះ គឺលោក [redacted] GUNANHUA មានសិទ្ធិត្រឹមត្រូវតាមច្បាប់ ដោយផ្អែកការប្រគល់សិទ្ធិពីក្រុមហ៊ុន[redacted] ដែលជាក្រុមហ៊ុនមេ តាមរយៈសេចក្តីសម្រេចរបស់ក្រុមសាភិបាល និងលិខិតប្រគល់ សិទ្ធិចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៨ ដែលជាភស្តុតាងទី២ ដែលខ្លួនបានដាក់ជូនតុលាការដើម្បីពិនិត្យរួចរាល់។ បន្ថែមពីនេះ សេចក្តីសម្រេចក៏ដូចជាការប្រគល់សិទ្ធិក៏មានចែងក្នុងលក្ខន្តិកៈរបស់ក្រុមហ៊ុន ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៨ របស់ក្រុមហ៊ុន [redacted] ដែលជាភស្តុតាងទី៣ ត្រង់ប្រការ៩ ប្រការ១០ និងប្រការ១១ ដែលបញ្ជាក់ច្បាស់ណាស់ថា លោក[redacted]GUNANHUA មានសិទ្ធិក្នុងការចុះកិច្ចព្រមព្រៀងសហការដាំដំណាំចេកខាងលើ ដើម្បីជាប្រយោជន៍ក្រុមហ៊ុន ។ ចំពោះកំណត់ហេតុប្រជុំអភិបាល ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៦ របស់ក្រុមហ៊ុន [redacted] លីមីតធីត ដែលជាក្រុមហ៊ុនមេ ដែលភ្ជាប់នូវពាក្យសុំ បញ្ចូលពិនិត្យចុះថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២២ ដែលមេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយបាន ដាក់ជូនមកតុលាការឱ្យពិនិត្យ គឺមានភាពមិនប្រក្រតី ដោយហេតុថា សេចក្តីសម្រេចចុះថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០១៤ កំណត់ហេតុកិច្ចប្រជុំចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២១ ក៏ដូចជាសេចក្តីសម្រេចផ្សេងៗ សុទ្ធតែមានបញ្ជាក់ពីសាការីនៅប្រទេសចិន ប៉ុន្តែ លើកលែងតែកំណត់ហេតុកិច្ចប្រជុំចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៦ តែប៉ុណ្ណោះ ដែលមិនបានបញ្ជាក់ពីសាការី ដូចនេះសរុបមកវិញ ទាក់ទងជាមួយកំណត់ហេតុកិច្ចប្រជុំអភិបាល ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៦ ដែលមេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយ តែងតែលើកឡើងថា កំណត់ហេតុកិច្ចប្រជុំនេះ បានកំណត់អំពីសារធាតុរបស់ខាងតំណាងក្រុមហ៊ុន មុននឹងចុះកិច្ចសន្យាត្រូវមានការសម្រេចពីក្រុមហ៊ុនមេ ជាពិសេសក្រោយពីភាគីទាំងពីរបានចុះកិច្ចព្រម ព្រៀងសហការដាំចេកខាងលើរួចរាល់ កូនក្តីខ្លួនក៏បានធ្វើការដាំដុះរួចរាល់លើដីប្រមាណជាង១០០ហិកតា នៃដីសរុប ចំនួន ២៥០០ ហិកតា ដែលមានទឹកប្រាក់សរុបប្រមាណ ១.៧៩០.៤១២,៩៩ (មួយលានចិត សិបប្រាំបួនម៉ឺនបួនរយដប់ពីរក្បៀសកៅសិបប្រាំបួនសេន) យេន បើយោងតាមរបាយការណ៍ស្តីពីទុន វិនិយោគចំណាយពាក់ព័ន្ធនឹងកិច្ចព្រមព្រៀងសហការដាំចេក លើផ្ទៃដីចំនួន ២.៥០០ ហិកតា ដែលមានបានដាក់ជូនមកតុលាការពិនិត្យ តាមរយៈជាភស្តុតាងលេខ៤, លេខ៥, លេខ៦ និងលេខ៧។ បន្ថែមពីនេះ កូនក្តីខ្លួនបានដាក់ឯកសារបញ្ជាក់អំពីប្រវត្តិប្រតិបត្តិការពីខែមិថុនា ខែកញ្ញា ឆ្នាំ២០២១ ជូនតុលាការផងដែរ ដែលជាភស្តុតាងលេខ៨។ ជាងនេះទៅទៀត



Scanned with CamScanner

កូនក្តីខ្លួនក៏បានផ្តល់នូវប្រាក់កក់ដីចំនួន ២០០០០០ (ម្ភៃម៉ឺន) ដុល្លារអាមេរិក ដោយមានបង្កាន់ដៃលេខ ៣៦៤៥៤៤០៦ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២១ ដែលជាភស្តុតាងលេខ៩ ព្រមទាំងប្រាក់ថ្លៃជួលបង់ពន្ធចំនួន ៤០០០០ (បួនម៉ឺន)ដុល្លារអាមេរិក ដោយមាន បង្កាន់ដៃលេខ ៣៦៥៤៤០៩ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២១ ជាភស្តុតាងតែម្តង និងប្រាក់កក់ដីចំនួន ១៦០០០០ (ដប់ប្រាំមួយម៉ឺន) ដុល្លារអាមេរិក ដោយមានបង្កាន់ដៃលេខ ៣៦៤៥០១៣ ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២១ ជាភស្តុតាងលេខ១០ស្រាប់។

-មេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយបានធ្វើសេចក្តីថ្លែងការណ៍តបថា ៖ ពាក់ព័ន្ធទៅនឹងចំណុចវិវាទទី១ ថា តើលោក [redacted] GUNANHUA មានសិទ្ធិចុះហត្ថលេខាលើធ្វើកិច្ចព្រមព្រៀង សហប្រតិបត្តិការដាំដំណាំចេកចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២១ រវាងក្រុមហ៊ុន[redacted] និងក្រុមហ៊ុន [redacted]? មុននឹងឈានចូលនូវសេចក្តីថ្លែងការណ៍ ខ្លួនសូមធ្វើការបញ្ជាក់ផងដែរថា [redacted]ជាក្រុមហ៊ុនមេ [redacted] ជាក្រុមហ៊ុនបុត្រសម្ព័ន្ធ។ ដូចនេះ ខ្លួនសូមធ្វើការថ្លែងការណ៍តបពាក់ព័ន្ធជាមួយវិវាទទី១ ពាក់ព័ន្ធនឹងសិទ្ធិតំណាងរបស់លោក [redacted] GUNANHUA គឺដំបូងឡើយលោក [redacted] GUNANHUA ត្រូវបានតែងតាំងជាអភិបាលដោយក្រុមហ៊ុនមេ ដើម្បីធ្វើជាអភិបាលរបស់ក្រុមហ៊ុនសម្ព័ន្ធ តាមរយៈសេចក្តីសម្រេចប្រគល់សិទ្ធិចុះថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០១៨ ប៉ុន្តែ ដោយឃើញថាមានភាពមិនប្រក្រតីនូវសកម្មភាពរបស់លោកអភិបាល ក្រុមហ៊ុនមេ[redacted] បានសម្រេចបញ្ចប់តំណែងរបស់ លោក [redacted]GUNANHUA តាមរយៈកំណត់ហេតុ ចុះថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០២១ ។ នៅក្នុងអំឡុងពេលលោក [redacted]GUNANHUA បានកាន់តំណែងជាអភិបាល របស់ក្រុមហ៊ុនសម្ព័ន្ធលោកបានប្រើប្រាស់សិទ្ធិជាអភិបាលចុះកិច្ចសន្យាសហប្រតិបត្តការដាំចេក ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២១ ជាមួយក្រុមហ៊ុន [redacted]ខ្លួនសុំហៅកាត់ថា [redacted]ចុះ ។ តាមរយៈការចុះកិច្ចសន្យានេះ កាលនោះលោក[redacted] GUNANHUA បានមិនបានទទួលការឯកភាពរហ័សមួយ ឬក៏ជាលាយលក្ខណ៍អក្សរណាមួយតាមរយៈ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ឬសេចក្តីសម្រេចណាមួយ របស់ក្រុមហ៊ុនមេទេ។ ជាក់ស្តែង ឃើញថាកន្លងមកក្រុមហ៊ុនមានការកំណត់មួយ ដែលបញ្ជាក់នូវទំហំសិទ្ធិអំណាចរបស់អភិបាល តាមរយៈកំណត់ហេតុចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៦ ចឹងខ្លួនសូមបញ្ចេញចាក់ខ្លឹមសារនេះបន្តិច។ សូមកត់សម្គាល់ថា ក្រុមហ៊ុនគឺសំដៅលើក្រុមហ៊ុនមេ ក្រុមហ៊ុន[redacted]ត្រូវបានតម្រូវឱ្យចុះហត្ថលេខាលើឯកសារឧបសម្ព័ន្ធ ដើម្បីឯកភាពលើកិច្ចការខាងក្រោមរបស់ក្រុមហ៊ុនបុត្រសម្ព័នឈ្មោះ [redacted] និងឯកភាពលើបញ្ហាសំខាន់ៗខាងក្រោមដែលត្រូវបានសម្រេច ដោយកិច្ចប្រជុំក្រុមប្រឹក្សាភិបាល ហើយសេចក្តីសម្រេចនឹងត្រូវឯកភាពដោយអភិបាលជាម្ចាស់ភាគហ៊ុន ដែលមានវត្តមានលើសពីមួយភាគពីរនៃសិទ្ធិបោះឆ្នោត ហើយឯកសារទាំងអស់ត្រូវបោះត្រាពាណិជ្ជការរបស់ ក្រុមហ៊ុន[redacted]និងចុះហត្ថលេខា ដើម្បីបញ្ជាក់ពីសេចក្តីសម្រេចត្រង់ចំណុចទី១ ដែលបង្ហាញអំពីសេចក្តីសម្រេចលើគោលនយោបាយអាជីវកម្ម និង ផែនការវិនិយោគរបស់ក្រុមហ៊ុន ដោយរាប់បញ្ចូលទាំងការចុះកិច្ចព្រមព្រៀងជួលបរទេស កម្ចីបរទេសដែលលើសពី ៣០០០ ០០០ (បីលាន)ដុល្លារអាមេរិក ឬគម្រោងសហការដែលលើសពី ៥០០០០០០ (ប្រាំលាន)ដុល្លារអាមេរិក ត្រូវមានការឯកភាពពីក្រុមហ៊ុនមេ ។ ប៉ុន្តែ ជាក់ស្តែងក្នុងការចុះហត្ថលេខា លោក [redacted] GUNAN HUA អត់មានការឯកភាពណាមួយពីក្រុមហ៊ុនមេនៃ។ ម៉្យាងទៀត ខ្លួនស្នើសុំឱ្យលោកស្រីចៅ ក្រមមេត្តាកត់សម្គាល់ត្រង់ចំណុចមួយថា ក្នុងអំឡុងពេលលោក [redacted] GUNANHUA កាន់តំណាងជា អភិបាលរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធ លោក [redacted] GUNANHUA ជាម្ចាស់ភាគហ៊ុនរបស់ក្រុមហ៊ុន[redacted]ផងដែរ ដែលនេះបង្ហាញពីភាពមិនប្រក្រតីមួយកើតឡើងក្នុងអំឡុងពេល បង្កើតកិច្ចសន្យាខាងលើ ដែលប៉ះពាល់ ដល់ផលប្រយោជន៍ដល់ក្រុមហ៊ុនបុត្រសម្ព័ន្ធ។ ផ្អែកទៅលើទំនាក់ទំនងគតិយុត្តខាងលើ យើងអាច សម្គាល់ឃើញថា លោក



Scanned with CamScanner

[redacted]GUNANHUA មានផលប្រយោជន៍ មានសិទ្ធិជាអ្នកតំណាងផង ស្របពេលដែលគាត់ជាម្ចាស់ភាគហ៊ុនរបស់ក្រុមហ៊ុន CBA ផងដែរ។ យោងតាមមាត្រា ៦១ អ្នកតំណាងពិសេស នៃ ក្រមរដ្ឋប្បវេណីបានចែងថា ចំពោះចំណុចដែលផលប្រយោជន៍របស់អភិបាល និងផលប្រយោជន៍របស់នីតិបុគ្គលប្រឆាំងគ្នា អភិបាលនោះពុំត្រូវមានសិទ្ធិតំណាងឡើយ។ ជាក់ស្តែង យោងតាមអង្គហេតុខាងលើ យើងបានពិនិត្យឃើញថា លោក[redacted]GUNANHUA ពុំមានសិទ្ធិគ្រប់គាន់ជាអ្នកតំណាង ក្នុងការចុះហត្ថលេខាពាក់ព័ន្ធការសហការជាមួយក្រុមហ៊ុន[redacted]នោះទេ។ ម៉្យាងទៀត ក្នុងករណីនេះផង ដែរខ្លួនសុំឱ្យលោកស្រីចៅក្រមមេត្តាពិចារណាត្រង់ចំណុចដែលក្រុមហ៊ុន [redacted] ជាតតិយជន និងបានដឹងដែរថាលោក[redacted]GUNANHUA មានសមាសភាពជាម្ចាស់ភាគក្រុមហ៊ុនរបស់ខ្លួនហើយ ក៏មានងារសិទ្ធិ ជាអភិបាលរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធផងដែរ ប៉ុន្តែនៅតែចុះកិច្ចសន្យាសហការជាមួយនឹងក្រុមហ៊ុន [redacted]ទៀត ដែលនេះបង្ហាញពីចេតនាទុច្ចរិតរបស់ក្រុមហ៊ុន [redacted]ផងដែរ ។ ចំពោះការថ្លែងការណ៍ លម្អិតខ្លួនបានដាក់សេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរជូនតុលាការផងដែរ ។

-មេធាវីតំណាងដោយអាណត្តិឱ្យដើមចោទបានធ្វើសេចក្តីថ្លែងការណ៍តបថា ៖ ទីមួយ ពាក់ព័ន្ធទៅនឹងការចុះកិច្ចព្រមព្រៀងរបស់ Mr. [redacted] គឺពុំចាំបាច់មានសេចក្តីសម្រេច អំពីការអនុញ្ញាតពីក្រុមហ៊ុនមេនោះទេ ដោយហេតុថាដូចបានបញ្ជាក់ខាងលើ Mr.[redacted]គាត់មានសិទ្ធិគ្រប់គ្រាន់តាមរយៈ សេចក្តីសម្រេចចុះថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០១៨ និងលក្ខន្តិកៈក្រុមហ៊ុនចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៨ រួចរាល់។ ទីពីរ ពាក់ព័ន្ធជាមួយនឹងការលើកឡើងថា កំណត់ហេតុចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៦ របស់ក្រុមហ៊ុនមេនេះដែលបានកំណត់អំពីទំហំកម្រិតសិទ្ធិរបស់អភិបាលរបស់ក្រុមហ៊ុន [redacted] នេះគឺ ខ្លួនបានបញ្ជាក់ជូនតុលាការអំបាញ់មិញដែលពាក់ព័ន្ធជាមួយកំណត់ហេតុនេះ មានភាពមិនប្រក្រតី បើប្រៀបធៀបទៅនឹងកំណត់ហេតុក៏ដូចជាសេចក្តីសម្រេចផ្សេងៗ ដែលមេធាវីតំណាងដោយអាណត្តិឱ្យ ចុងចម្លើយបានដាក់ពាក្យបណ្តឹលក៏ដូចជាឱ្យតុលាការពិនិត្យភស្តុតាង តាមរយៈពាក្យសុំបណ្តឹល និងពិនិត្យភស្តុងតាងចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០២២។ ដូចនេះ ខ្លួនស្នើសុំឱ្យតុលាការពិនិត្យពិចារណាទៅលើ កំណត់ហេតុចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៦ នេះទៅលើភាពមិនប្រក្រតីដែលខ្លួនបានលើកឡើង។ ទីបី ពាក់ព័ន្ធជាមួយការលើកឡើងថា Mr.[redacted]ជាអភិបាលរបស់ក្រុមហ៊ុន [redacted]ង និងជាសមាជិកជាតំណាងជាភិបាលរបស់ក្រុមហ៊ុន [redacted] ផង សូមបញ្ជាក់ជូនថា ទីមួយការចុះកិច្ចព្រមព្រៀង ពេលនេះមិនមែនជាប្រយោជន៍របស់ Mr. [redacted] គឺជាប្រយោជន៍របស់ក្រុមហ៊ុន [redacted] គឺទាំងលុយកក់ថ្លៃដី ទាំងជួយបង់ថ្លៃឈ្នួលគឺបានបញ្ជាក់ច្បាស់ណាស់ត្រូវប្រគល់ទៅឱ្យក្រុមហ៊ុន [redacted]មិនមែនប្រគល់ឱ្យ Mr.[redacted]នោះទេ។ ម៉្យាងវិញទៀត អភិបាលមួយនៅក្នុង ក្រុមហ៊ុនមួយក៏មានច្បាប់ចែងថា គាត់មិនមានសិទ្ធិទៅលើថាគាត់មិនមែនជាម្ចាស់ភាគហ៊ុនលើក្រុមហ៊ុន មួយទៀតដែរ ។ ទីបួន ពាក់ព័ន្ធជាមួយមាត្រា៦១ ក៏បានបញ្ជាក់យ៉ាងច្បាស់ថា ចំពោះចំណុចដែលផល ប្រយោជន៍របស់អភិបាល និងផលប្រយោជន៍របស់នីតិបុគ្គលប្រឆាំងគ្នា អភិបាលនោះពុំត្រូវមានសិទ្ធិតំណាងឡើយ។ ពាក់ព័ន្ធនូវចំណុចនេះ ដូចខ្លួនបានបញ្ជាក់ជូននូវការថ្លែងការណ៍ទី៣ គឺផលប្រយោជន៍ របស់បុគ្គល [redacted] GUANHUA ជាមួយក្រុមហ៊ុនចុងចម្លើយមិនមានការប្រឆាំងគ្នានោះទេ។ សូមបញ្ជាក់ពី ការប្រគល់លុយនេះ គឺមានការប្រគល់ទទួល មានបង្កាន់ដៃចេញដោយក្រុមហ៊ុន [redacted]ផ្ទាល់ ហើយ Transition ក៏ដូចជាឯកសារប្រតិបត្តិការធនាគារមានបញ្ជាក់យ៉ាងច្បាស់ថា ប្រាក់នេះ ចូលទៅក្នុងក្រុមហ៊ុន [redacted] មិនមែនចូលទៅបុគ្គល Mr. [redacted]នោះទេ។ យោងតាមលក្ខន្តិកៈដែលខាងមេធាវីតំណាងឱ្យចុងចម្លើយដាក់ជូនមកគឺ ជាអភិបាលរបស់ក្រុមហ៊ុន[redacted]។

-មេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយបានធ្វើសេចក្តីថ្លែងការណ៍តបថា ៖ ត្រង់ចំណុចនេះដែលខ្លួនសូមឱ្យលោកស្រីចៅក្រមពិចារណាមាត្រា៥៧ នៃក្រមរដ្ឋប្បវេណី ករណីយកិច្ចរបស់អភិបាលបានចែងថា អភិបាលមានករណីយកិច្ចត្រូវគោរពទៅតាមច្បាប់ បទដ្ឋានគតិយុត្ត និងខ្លឹមសារនៃលក្ខន្តិកៈ និងត្រូវចាត់ចែងការងាររបស់នីតិបុគ្គលដោយស្មោះត្រង់។ ក្នុងករណីនេះ បានបង្ហាញឃើញថាលោក



Scanned with CamScanner

[redacted] GUNANHUA គាត់មានចេតនាទុច្ចរិត ដែលសមគំនិតជាមួយក្រុមហាហ៊ុន [redacted] ដើម្បីចុះកិច្ចព្រមព្រៀង ដែលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ផលប្រយោជន៍របស់ក្រុមហ៊ុនមេ ។ បន្ថែមពីនេះ សូមឱ្យលោកស្រីមេត្តាពិចារណាទៅលើការកម្រិតសិទ្ធិតំណាង ការកម្រិតដែលបានធ្វើលើសិទ្ធិតំណាងរបស់អភិបាល ឬអ្នកតំណាងនីតិបុគ្គលផ្សេងទៀត ពុំអាចតតាំងចំពោះតតិយជនសុចរិតបានឡើយ។ ត្រង់ចំណុចនេះក្រុមហ៊ុន [redacted] មិនអាចចាត់ទុកថាជាតតិយជនសុចរិតនោះទេ តែថានៅក្នុងអំឡុងពេលចុះកិច្ចសន្យាក្រុមហ៊ុន [redacted] បានយល់ច្បាស់តំណែងលោក [redacted] GUNANHUA ដែលគាត់ជាអភិបាលរបស់ក្រុមហ៊ុន [redacted] ហើយគាត់ក៏ជាម្ចាស់ភាគហ៊ុនរបស់ [redacted] ផងដែរ។ ដូចនេះ មិនអាចចាត់ទុកថា គាត់តតិយជនសុចរិតបានទេ។ ប៉ុន្តែ ត្រង់រឿងមួយទៀតត្រង់មាត្រា ៣៧២ ការតំណាងដែលមានលក្ខណៈជារូបភាព ក្នុងករណីដែលអ្នកតំណាងធ្វើកិច្ចសន្យា ដោយហួសពីទំហំនៃសិទ្ធិ តំណាង ប្រសិនបើភាគីម្ខាងទៀតជឿជាក់ថា អ្នកតំណាងមានសិទ្ធិតំណាងចំពោះកិច្ចសន្យានោះ ហើយគ្មានកំហុសក្នុងការជឿនោះទេ ម្ចាស់សិទ្ធិត្រូវទទួលខុសត្រូវក្នុងការអនុវត្តកិច្ចសន្យានោះ ចំពោះភាគីម្ខាងទៀត។ ប៉ុន្តែត្រង់ចំណុចនេះ ដូចខ្លួនបានលើកឡើងដដែលៗថា [redacted] បានដឹងច្បាស់អំពីតំណែងរបស់លោក [redacted] GUNANHUA ទាំងក្រុមហ៊ុន [redacted] ទាំងក្រុមហ៊ុន [redacted] នេះ ដែលបង្ហាញពីចេតនាទុច្ចរិត និងកំហុសយ៉ាងធ្ងន់ធ្ងរក្នុងការជឿរបស់ក្រុមហ៊ុន [redacted] ដែលបានចុះកិច្ចសន្យាជាមួយលោក [redacted] GUNANHUA។ ដូច្នេះ ក្រុមហ៊ុន [redacted] ក្នុងនាមជាក្រុមហ៊ុនមេ [redacted] ពុំមានភាពចាំបាច់ក្នុងការទទួលខុសត្រូវអនុវត្តកិច្ចសន្យាកិច្ចសហការប្រត្តិបតិការជាំចេក ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០២១ ចំពោះភាគីម្ខាងទៀតដែលជាក្រុមហ៊ុន [redacted]។ ម្យ៉ាងទៀត កិច្ចសន្យានេះបើសិនជាយើងពិចារណាលើសិទ្ធិអំណាចរបស់ លោក [redacted] GUNANHUA ថាគាត់មានទំនាស់ផលប្រយោជន៍រវាងក្រុមហ៊ុន [redacted] ជាមួយក្រុមហ៊ុន [redacted] គឺអាចចាត់ទុកបានថា កិច្ចសន្យាគឺគ្មានអានុភាពអនុវត្តតាំងពីចាប់ផ្តើម។ ចំពោះផលប៉ះពាល់ជាក់ស្តែង វាបំពានទៅនឹងការកម្រិតនូវសិទ្ធិតំណាង ហើយការប៉ះពាល់ផលប្រយោជន៍ នៅមិនទាន់អាចបកស្រាយនាពេលនេះបានទេ ។

-មេធាវីតំណាងដោយអាណត្តិឱ្យដើមចោទបានធ្វើសេចក្តីថ្លែងការណ៍ចុងក្រោយថា ៖ ក្នុងនាមជាមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទ ខ្លួននៅតែរក្សាការទាមទារដូចមានដែលនៅក្នុងពាក្យបណ្តឹងដដែល ។

-មេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយបានធ្វើសេចក្តីថ្លែងការណ៍ចុងក្រោយថា ៖ ក្នុងនាមជាមេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយ ខ្លួនស្នើសុំឱ្យតុលាការសម្រេចច្រានចោលការទាមទាររបស់ដើមចោទ ។

## សំអាងហេតុ

**១-យល់ឃើញថា** ៖ មេធាវីតំណាងដោយអាណត្តិឱ្យដើមចោទបានធ្វើសេចក្តីថ្លែងការណ៍ ដោយបានស្នើសុំឱ្យតុលាការចេញសេចក្តីសម្រេច ដែលមានខ្លឹមសារថាទាមទារកុំឱ្យអនុញ្ញាតអនុវត្តដោយបង្ខំចំពោះម្ចាស់បំណុលនៃការអនុវត្តទៅលើដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នលេខ ៤៦៥ “ធ” ដ.រ ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ និងប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ ។

**២-យល់ឃើញថា** ៖ នាពេលទាញហេតុផលដោយផ្ទាល់មាត់ មេធាវីតំណាងដោយអាណត្តិឱ្យដើមចោទបានធ្វើសេចក្តីថ្លែងការណ៍ថា ពាក់ព័ន្ធនឹងចំណុចវិវាទទី១ ខ្លួនសូមបញ្ជាក់ថា ការចុះសហការជាំចេកខាងលើនេះ លោក [redacted] GUNANHUA មានសិទ្ធិត្រឹមត្រូវតាមច្បាប់ ដោយផ្អែកការប្រគល់សិទ្ធិពីក្រុមហ៊ុន [redacted] ដែលជាក្រុមហ៊ុនមេ តាមរយៈសេចក្តីសម្រេចរបស់ក្រុមសាភិបាល និងលិខិតប្រគល់សិទ្ធិចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៨ ។ បន្ថែមពីនេះ សេចក្តីសម្រេចក៏ដូចជាការប្រគល់សិទ្ធិក៏មានចែងក្នុងលក្ខន្តិកៈរបស់ក្រុមហ៊ុន ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៨ របស់ក្រុមហ៊ុន [redacted]



Scanned with CamScanner

ត្រង់ប្រកា៩ ប្រកា១០ និងប្រកា១១ ដែលបញ្ជាក់ច្បាស់ណាស់ថា លោក[redacted] GUNANHUA មានសិទ្ធិក្នុងការចុះកិច្ចព្រមព្រៀងសហការដាំដំណាំចេកខាងលើ ដើម្បីជាប្រយោជន៍ក្រុមហ៊ុន ។

តុលាការយល់ឃើញថា ការលើកឡើងរបស់មេធាវីខាងលើមានមូលហេតុ និងភស្តុតាងច្បាស់លាស់ ដែលអាចឱ្យជឿជាក់បាន។ តាមការពិនិត្យលើសេចក្តីសម្រេចរបស់ក្រុមសាភិបាល និងលិខិតប្រគល់សិទ្ធិចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៨ ព្រមទាំងលក្ខន្តិកៈរបស់ក្រុមហ៊ុន ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៨ របស់ក្រុមហ៊ុន[redacted] ត្រង់ប្រកា៩ ប្រកា១០ និងប្រកា១១ បង្ហាញថា លោក [redacted] GUNANHUA គឺពិតជាមានតួនាទីជាអភិបាលរបស់[redacted] ដែលត្រូវបានតែងតាំងដោយក្រុមហ៊ុន[redacted] ជាក្រុមហ៊ុនមេ ពិតមែន ។ ដូច្នេះ លោក [redacted] GUNANHUA ក្នុងនាមជាអភិបាលរបស់ក្រុមហ៊ុន មានសិទ្ធិក្នុងការចុះកិច្ចព្រមព្រៀងផ្សេងៗ ដើម្បីផល ប្រយោជន៍របស់ក្រុមហ៊ុនហ្គ្រីន[redacted] ដែលជាក្រុមហ៊ុនមេ។ ម្យ៉ាងទៀត ផ្អែកលើកិច្ចព្រមព្រៀងសហប្រតិបត្តិការដាំដំណាំចេករវាងដើមចោទ និងចុងចម្លើយ ឃើញថា កិច្ចព្រមព្រៀងនោះបានចុះហត្ថលេខា និងបោះត្រា[redacted] ត្រឹមត្រូវ ។

៣-យល់ឃើញថា ៖ បន្ថែមពីនេះ មេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយបានលើកឡើងថា ដោយឃើញមានភាពមិនប្រក្រតីនូវសកម្មភាពរបស់លោកអភិបាល ក្រុមហ៊ុនមេដែលជាក្រុមហ៊ុន [redacted] បានសម្រេចបញ្ចប់តំណែងរបស់លោក [redacted] GUNANHUA តាមរយៈកំណត់ហេតុ ចុះថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០២១ ។ តុលាការយល់ឃើញថា ភាពមិនប្រក្រតីក្នុងការបំពេញមុខតំណែងរបស់លោក[redacted]GUNANHUA ជាកិច្ចការផ្ទៃក្នុងរបស់ក្រុមហ៊ុន[redacted] ប៉ុណ្ណោះ មានន័យថា ចុងចម្លើយមិនអាចយកមូលហេតុបញ្ហាផ្ទៃក្នុងរបស់ក្រុមហ៊ុន ដើម្បីជាមូលហេតុបញ្ចប់រាល់កិច្ចព្រមព្រៀងដែលបានធ្វើជាមួយក្រុមហ៊ុនដើមចោទឡើយ ។ ដើម្បីឱ្យចុងចម្លើយអាចរួចផុតពីការទទួលខុសត្រូវលើកិច្ចព្រមព្រៀងដាំដំណាំចេក ដែលលោក [redacted] GUNANHUA ចុះហត្ថលេខាជាមួយដើមចោទបាន ចុងចម្លើយត្រូវតែបង្ហាញអំពីវិការៈនៃកិច្ចព្រមព្រៀង និងការខូចខាតដែលក្រុមហ៊ុនចុងចម្លើយបានទទួល ប៉ុន្តែចុងចម្លើយមិនអាចបញ្ជាក់អំពីវិការៈដែលកើតមាននៅក្នុងកិច្ចព្រមព្រៀងនោះមកកាន់តុលាការបានទេ ។

៤-យល់ឃើញថា ៖ មេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយបានលើកឡើងថា ការប្រើប្រាស់សិទ្ធិអំណាចរបស់លោក [redacted] GUNANHUA បង្ហាញថា គាត់មានទំនាស់ផលប្រយោជន៍រវាងក្រុមហ៊ុន CBA ជាមួយក្រុមហ៊ុនហ្គ្រីនអាយលេន គឺអាចចាត់ទុកបានថា កិច្ចសន្យាគ្មានអានុភាពអនុវត្តតាំងពីចាប់ផ្តើម ។ ចំពោះផលប៉ះពាល់ជាក់ស្តែង វាបំពានទៅនឹងការកម្រិតនូវសិទ្ធិតំណាង ហើយការប៉ះពាល់ផលប្រយោជន៍ នៅមិនទាន់អាចបកស្រាយនាពេលនេះបានទេ ។

តុលាការយល់ឃើញថា ការលើកឡើងរបស់មេធាវីខាងលើ ពុំមានមូលដ្ឋានត្រឹមត្រូវឡើយ ដោយហេតុថា ចុងចម្លើយមិនអាចបកស្រាយបានថា ទំនាស់ផលប្រយោជន៍រវាងដើមចោទ និងចុងចម្លើយកើតមាននៅចំណុចណាមួយ។ ម្យ៉ាងទៀត តាមរយៈសំអាងហេតុទី២ និងសំអាងហេតុទី៣ បង្ហាញយ៉ាងច្បាស់ថា លោក [redacted] GUNANHUA មានសិទ្ធិក្នុងការចុះកិច្ចព្រមព្រៀងជាមួយដើមចោទ និងមិនមានចំណុចណាមួយបង្ហាញថា កិច្ចព្រមព្រៀងខាងលើមានវិការៈឡើយ មានន័យថា កិច្ចព្រមព្រៀងរវាងដើមចោទ និងចុងចម្លើយនៅតែមានអានុភាពអនុវត្តដដែល។ បន្ថែមពីនេះ ចុងចម្លើយមិនអាចបង្ហាញមកកាន់តុលាការថា ក្រោយពេលដែលលោក [redacted] GUNANHUA (ក្នុងនាមជាអភិបាលក្រុមហ៊ុន របស់ចុងចម្លើយ) ចុះកិច្ចព្រមព្រៀងដាំដំណាំចេកជាមួយដើមចោទហើយ នាំឱ្យមានការប៉ះពាល់ផលប្រយោជន៍អ្វីខ្លះ ដល់ក្រុមហ៊ុនចុងចម្លើយនោះទេ ។



Scanned with CamScanner

**៥-យល់ឃើញថា** ៖ មួយវិញទៀត ផ្អែកតាមការលើកឡើងរបស់មេធាវីតំណាងដោយអាណត្តិឱ្យដើមចោទ បានបញ្ជាក់ផងដែរថា ក្រោយចុះកិច្ចព្រមព្រៀងរួច និងយោងតាមលក្ខខណ្ឌនៃកិច្ចព្រមព្រៀងនេះ ដើមចោទបានប្រគល់លុយកក់ថ្លៃដី និងលុយបង់ថ្លៃឈ្នួលទៅឱ្យក្រុមហ៊ុន [redacted] មិនមែនប្រគល់ឱ្យ Mr. [redacted] នោះទេ ។ ក្នុងនោះរួមមាន ការប្រគល់ទទួលមានបង្កាន់ដៃចេញដោយ [redacted]ផ្ទាល់ ហើយ Transition ក៏ដូចជាឯកសារប្រតិបត្តិការធនាគារមានបញ្ជាក់យ៉ាងច្បាស់ថា ប្រាក់នេះចូលទៅក្នុងក្រុមហ៊ុន ហ្វ្រ៊ីន អាយលែន ខេមបូឌា មិនមែនចូលទៅបុគ្គល Mr. [redacted] នោះទេ។ ចំណែក មេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយមិនបានបង្ហាញភស្តុតាង ក៏ដូចជាការជំទាស់អំពីការលើកឡើងរបស់មេធាវីតំណាងដោយអាណត្តិឱ្យដើមចោទឡើយ ដូច្នេះ ការដែល ចុងចម្លើយមិនបានបង្ហាញឆន្ទៈតវ៉ាអំពីអង្គហេតុដែលបានលើកឡើងខាងលើ តុលាការចាត់ទុកថា ចុងចម្លើយបានសារភាពអំពីអង្គហេតុនោះ ដោយផ្អែកទៅតាមបញ្ញត្តិមាត្រា៩៦ ចំណុច១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

ចំណុចខាងលើនេះ បង្ហាញឱ្យឃើញថា ការចុះកិច្ចព្រមព្រៀងរវាងដើមចោទលោក [redacted] GUNAN HUA (ក្នុងនាមជាអភិបាលក្រុមហ៊ុនរបស់ចុងចម្លើយ) ពុំបានធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍ណាមួយក្នុងក្រុមហ៊ុនចុងចម្លើយឡើយ ដោយហេតុថា លោក [redacted] GUNANHUA ចុះហត្ថលេខាលើកិច្ចព្រមព្រៀងនោះក្នុងនាមតំណាងផលប្រយោជន៍ឱ្យចុងចម្លើយ ហើយដើមចោទបានប្រគល់លុយកក់ថ្លៃដី និងលុយបង់ថ្លៃឈ្នួលទៅឱ្យក្រុមហ៊ុន [redacted] តាមរយៈគណនីធនាគាររបស់ចុងចម្លើយដោយផ្ទាល់ ដោយមិនមានផ្ទេរលុយចូលគណនីធនាគារលោក [redacted] GUNANHUA ទេ ។

**៦-យល់ឃើញថា** ៖ តាមរយៈសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល និងលិខិតប្រគល់សិទ្ធិចុះថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០១៨ ឃើញថា បានតែងតាំងលោក [redacted] GUNANHUA ជាតំណាង និងអភិបាលនៃក្រុមហ៊ុន [redacted] ហើយបានផ្តល់សិទ្ធិឱ្យលោក [redacted] GUNANHUA ក្នុងការចុះហត្ថលេខា និងផ្តិតស្នាមម្រាមដៃលើពាក្យស្នើសុំ និងឯកសារផ្សេងៗទៀតដែលពាក់ព័ន្ធលើកិច្ចព្រមព្រៀងទាំងអស់ ។ ដូច្នេះ លោក [redacted] GUNANHUA មានសិទ្ធិពេញលេញ ដើម្បីចុះកិច្ចព្រមព្រៀងជាមួយដើមចោទ ។

**៧-យល់ឃើញថា** ៖ ផ្អែកតាមសំអាងហេតុទី២, សំអាងហេតុទី៣, សំអាងហេតុទី៤, សំអាងហេតុទី៥ និងសំអាងហេតុទី៦ ខាងលើ បញ្ជាក់បានយ៉ាងច្បាស់ថា កិច្ចព្រមព្រៀងដាំដំណាំចេក ដែលបានធ្វើឡើងដោយលោក [redacted] GUNANHUA ជាមួយដើមចោទ មិនមានវិការៈណាមួយ និងមិនបានធ្វើឱ្យខូចខាតដល់ផលប្រយោជន៍របស់ក្រុមហ៊ុនរបស់ចុងចម្លើយឡើយ ។ ផ្ទុយទៅវិញ លិខិតជូនដំណឹងស្តីពីការអនុវត្តដោយស្ម័គ្រចិត្តលេខ១៨៥ អ.យ.ក ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២១ ដែលមានក្លូនបំណុល នៃការអនុវត្តឈ្មោះ [redacted] GUANHUA និងតតិយជនទាំងអស់ដែលកំពុងស្នាក់នៅជួលអាស្រ័យផលប្រកបអាជីវកម្មផ្សេងៗ ឬធ្វើការរៀទាំងឡាយក្នុងទីតាំងដីចំការ និងរោងចក្រខាងលើនេះ ធ្វើការរុះរើ ឥវ៉ាន់ និងសម្ភារៈទាំងអស់ដែលជាកម្មសិទ្ធិរបស់ខ្លួនចេញឱ្យអស់ ព្រមទាំងចាកចេញពីទីតាំងដីចំការ និងរោងចក្រខាងលើនេះ ឱ្យបានមុនថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២១ វេលាម៉ោង ៩៖០០នាទីព្រឹក ជាកំហិត បើមិនដូច្នេះទេ តំណាងអយ្យការនឹងចុះអនុវត្តដោយបង្ខំ តាមអំណាចដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នលេខ ៤៥៦ “ធ” ដ.រ ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ ពិតជាបានធ្វើឱ្យខូចខាតប្រយោជន៍របស់ដើមចោទ ដែលជាតតិយជនកាន់កាប់ដីដោយស្របច្បាប់ ស្របតាមកិច្ចព្រមព្រៀងសហការដាំចេកចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២១ មែន ដោយសារដើមចោទ បានចំណាយទុនវិនិយោគជាច្រើន និងបានបង់ថ្លៃកក់ រួមទាំងថ្លៃជួលដីរួចរាល់ឱ្យទៅចុងចម្លើយ។ ដូច្នេះ គប្បីតុលាការសម្រេចតាមពាក្យបណ្តឹងរបស់ដើមចោទ ។

**៨-យល់ឃើញថា** ៖ ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ តាមបញ្ញត្តិមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។



Scanned with CamScanner

## សេចក្តីសម្រេចបញ្ជាប់

១.ការអនុវត្តដោយបង្ខំចំពោះកម្មវត្ថុ នៃការអនុវត្តដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នលេខ ៤៦៥ "ធ" ដ.រ ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រូវហាមឃាត់ ។

២.ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ ។

ថ្ងៃព្រហស្បតិ៍ ១២កើត ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

ធ្វើនៅក្រចេះ: ថ្ងៃទី២១ ខែមីនា ឆ្នាំ២០២៤

ចៅក្រម ហត្ថលេខា និងត្រា

[redacted]

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃពុធ ២រោច ខែចេត្រ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

ធ្វើនៅក្រចេះ: ថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៤

**ក្រឡាបញ្ជី**

[redacted]

បានឃើញ

**ចៅក្រម**

[redacted]



Scanned with CamScanner